# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# សាលដីកាស្ថាពរក្នុងសំណុំរឿង ០០១ នាពេលខាងមុខ

ខែមករា ឆ្នាំ ២០១២

## កាលប្បវត្តិ

**១៨ កក្កដា ២០០៧** — សហព្រះរាជអាជ្ញាចេញ**សេចក្ដីសន្និដ្ឋានស្ថាពរទី១** សំណូមពរសហចៅក្រមស៊ើបអង្កេត ឲ្យធ្វើការស៊ើបអង្កេតទៅលើ នួន ជា, អៀង សារី, អៀង ធិរិទ្ធ, ខៀវ សំផន និង កាំង ហ្គេកអ៊ាវ ហៅ ឌុច។

**៣១ កក្កដា ២០០៧** — ឌុច ត្រូវបានបញ្ជូនពីមន្ទីរឃុំឃាំងរបស់តុលាការយោធា មកមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។

**១៩ កញ្ញា ២០០៧** — សហចៅក្រមស៊ើបអង្កេតបែងចែកសំណុំរឿងជាពីរ ដោយប្រកាស ថា ឌុច នឹងត្រូវកាត់ទោសដាច់ដោយឡែកពីជនត្រូវចោទបួនរូបទៀត។

**៨ សីហា ២០០៨** — សហចៅក្រមស៊ើបអង្កេតចេញ**ដីកាដំណោះស្រាយ** ដោយចោទប្រកាន់ ឌុច ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុង ហ្សឺណែវឆ្នាំ១៩៤៩ និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។

**៥ ធ្នូ ២០០៨** — តាមបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះសាលាដំបូងធ្វើវិសោធនកម្មលើបទចោទប្រកាន់ដោយបន្ថែមមនុស្សឃាតនិងការធ្វើទា-រុណកម្ម នៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

**១៧-១៨ កុម្ភៈ ២០០៨** — អង្គជំនុំជម្រះសាលាដំបូងបើក**សវនាការបឋម**លើសំណុំរឿង ០០១

**៣០ មីនា ២០០៩** — អង្គជំនុំជម្រះសាលាដំបូងចាប់ផ្ដើម**សវនាការលើ អង្គ**

**២៣-២៧ វិច្ឆិកា ២០០៩** — អង្គជំនុំជម្រះសាលាដំបូងស្ដាប់**សេចក្ដីសន្និដ្ឋានបញ្ចប់**ក្នុងសំណុំរឿង ០០១។ មេធាវីការពារក្ដីស្នើសុំឲ្យតុលាការលើកលែងការចោទប្រកាន់ ឌុច ចំណែកសហព្រះរាជអាជ្ញាស្នើសុំឲ្យតុលាការដាក់ពន្ធនាគារ ឌុច រយៈពេល៤០ឆ្នាំ។

**២៦ កក្កដា ២០១០** — អង្គជំនុំជម្រះសាលាដំបូងបានចេញនូវសាលក្រម លើអង្គសេចក្ដី។

**១៦ សីហា ២០១០** — សហព្រះរាជអាជ្ញាជូនដំណឹងអំពីការដាក់ពាក្យបណ្ដឹង សាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ បន្ទាប់មក សហព្រះរាជ អាជ្ញាបានដាក់ពាក្យបណ្ដឹងសាទុក្ខនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។

**២៤ សីហា ២០១០** — មេធាវីការពារក្ដីជូនដំណឹងអំពីការដាក់ពាក្យបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្ដីដាក់សារណាបណ្ដឹងសាទុក្ខនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០។ រីឯដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១,២,៣ ក៏បានជូនដំណឹងដាក់ពាក្យបណ្ដឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ បន្ទាប់មកក៏បានដាក់សារណាបណ្ដឹងសាទុក្ខនៅថ្ងៃទី ៦ ខែតុលា និងថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ២០១០។

**២៨-៣០ មីនា ២០១១** — អង្គជំនុំជម្រះតុលាការកំពូលបើកសវនាការលើបណ្ដឹង សាទុក្ខក្នុងសំណុំរឿង ០០១។

**៣ កុម្ភៈ ២០១២** — អង្គជំនុំជម្រះតុលាការកំពូលប្រកាសសាលដីកា លើបណ្ដឹងសាទុក្ខ

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# សាលដីកាស្ថាពរក្នុងសំណុំរឿង ០០១ នាពេលខាងមុខ

ខែមករា ឆ្នាំ ២០១២

## អំពីជនត្រូវចោទ



**ឈ្មោះ** កាំង ហ្កេកអ៊ាវ ហៅ ឌុច

**កាលបរិច្ឆេទនិងទីកន្លែងកំណើត:** ១៧ វិច្ឆិកា ឆ្នាំ ១៩៤២ នៅខេត្តកំពង់ធំ

**តួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ:** អនុលេខា ក្រោយមកជាលេខា មន្ទីរ ស-២១ (មន្ទីរសន្តិសុខដែលត្រូវបានស្គាល់ថាជា គុកទួលស្លែង)

**កាលបរិច្ឆេទដីកាឃុំខ្លួនបណ្តោះអាសន្នលើកទី១០:** ៣១ កក្កដា ២០០៧

## អំពីសវនាការ

ឌុច ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅមន្ទីរ ស-២១ និងនៅទីតាំងផ្សេងទៀតដែលជាប់ពាក់ព័ន្ធ ក្នុងអំឡុងរបបខ្មែរក្រហម។ សវនាការលើអង្គសេចក្តីនៅអង្គជំនុំជម្រះសាលាដំបូង៖

- ពីថ្ងៃទី៣០ មីនា ២០០៩ ដល់ថ្ងៃទី២៧ កក្កដា ២០០៩ សរុបរយៈពេល ៧៧ ថ្ងៃ

អង្គសវនាការបានស្តាប់សម្តីសាក្សីចំនួន ៥៥ នាក់រួមមាន ១៧ នាក់ជាសាក្សីអង្គហេតុ ៩ នាក់ជាអ្នកជំនាញ ៧ នាក់ជាសាក្សីទៅលើចរិតលក្ខណៈ និង ២២នាក់ជាដើមបណ្តឹងរដ្ឋប្បវេណី។

មេធាវីការពារក្តីស្នើសុំលើកលែងការចោទប្រកាន់ ប៉ុន្តែសហព្រះរាជអាជ្ញាស្នើសុំឲ្យដាក់ពន្ធនាគាររយៈពេល៤០ឆ្នាំ។

## អំពីសាលក្រម

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ឌុច មានពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ឌុច ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ។ សាលក្រមបានកាត់បន្ថយ ៥ឆ្នាំជាការទូទាត់សងសម្រាប់ការដែល ឌុច ត្រូវតុលាការយោធាឃុំខ្លួនដោយខុសនីតិវិធីច្បាប់ចន្លោះពីខែឧសភា ឆ្នាំ១៩៩៩ ដល់ខែកក្កដា ឆ្នាំ២០០៧។ អង្គជំនុំជម្រះសាលាដំបូងក៏បានទទួលស្គាល់ដើមបណ្តឹង រដ្ឋប្បវេណីចំនួន៦៦នាក់ ក្នុងចំណោមពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណីចំនួន៩០ និងបានផ្តល់សំណងផ្លូវចិត្តនិងសមូហភាព ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

## សវនាការលើបណ្តឹងសាទុក្ខ

អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការលើបណ្តឹងសាទុក្ខ នៅថ្ងៃទី២៨-៣០ មីនា ឆ្នាំ ២០១១ ហើយបានស្តាប់ការជជែក ដោយផ្ទាល់មាត់ពីភាគីនានាលើប្រធានបទចំនួន៤គឺយុត្តាធិកាបុគ្គល ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការផ្តន្ទាទោស និងបណ្តឹងសាទុក្ខរបស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី។ អំឡុងពេលសវនាការ ឌុចនិងក្រុមមេធាវីការពារក្តីរបស់ខ្លួនស្នើសុំឲ្យតុលាការឲ្យដោះលែងគាត់ ខណៈព្រះរាជអាជ្ញាបានស្នើឲ្យមានការផ្តន្ទា ទោសដាក់គុកអស់មួយជីវិត។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឲ្យពាក្យសុំតាំងខ្លួនដែលច្រានចោលត្រូវបានទទួលស្គាល់ និងផ្តល់នូវសំណងប្រកបដោយអត្ថន័យកាន់តែខ្លាំងឡើង។

## មូលហេតុនៃបណ្តឹងសាទុក្ខ

សហព្រះរាជអាជ្ញាបានអះអាងថា៖១)សាលក្រមពុំបានផ្តល់ទម្ងន់គ្រប់គ្រាន់ ទៅលើស្ថានទម្ងន់នៃបទឧក្រិដ្ឋ ដែលបានប្រព្រឹត្ត ២)សាលក្រមបានផ្តល់ស្ថានសម្រាលទោសហួសហេតុ និង ៣) ឌុច គួរតែត្រូវផ្តន្ទាទោសបន្ថែមទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ សម្រាប់ការដាក់ជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការសម្លាប់រង្គាល និងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀត ក៏ដូចជាការធ្វើឲ្យទៅជាទាសករនូវអ្នកទោសនៃមន្ទីរ ស-២១។

មេធាវីការពារក្តីអះអាងថា៖ ១) អង្គជំនុំជម្រះតុលាការកំពូលគួរតែលើកលែងការចោទប្រកាន់ ឌុច ព្រោះគាត់ពុំស្ថិតនៅក្នុងក្រុមបុគ្គលដែលស្ថិតក្រោមដែនយុត្តាធិការរបស់ អ.វ.ត.ក ឡើយ និង ២) ការផ្តន្ទាទោស ឌុច គួរតែ អនុលោមតាមនីតិវិធីដែលចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាថ្មីឆ្នាំ២០០៩។

ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣ក្រុម សរុប៤១នាក់ (រួមទាំងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២នាក់ដែលត្រូវបដិសេធ) ក៏បានដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ដោយអះអាងថា: ១) ពួកគេគួរតែត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ ២) តុលាការគួរតែផ្តល់សំណងផ្លូវចិត្តនិងសមូហភាពដែលមាន លក្ខណៈសមរម្យជាងនេះ។

## ដំណើរការបច្ចុប្បន្ន

អង្គជំនុំជម្រះតុលាការកំពូលនឹងប្រកាសសាលដីកាលើបណ្តឹងសាទុក្ខនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ ២០១២។ សេចក្តីសម្រេចនេះនឹងជាសេចក្តីសម្រេចចុងក្រោយ ហើយបិទផ្លូវតវ៉ា ដែលជាការបិទបញ្ចប់សំណុំរឿង ០០១ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។